អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គនាយកដ្ឋានស្រាវជ្រាវ
នាយកដ្ឋានស្រាវជ្រាវថវិកា

# ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច

**មាតិកា៖**

- ពាណិជ្ជកម្មកម្ពុជាជាមួយសហភាពអឺរ៉ុបមានតម្លៃ ៣,៨ ប៊ីលានដុល្លារ នៅឆ្នាំ ២០២០
- បន្ទះឈើបរបស់ប្រទេសជប៉ុនសម្រាប់ប្រព័ន្ធនាវាកម្ពុជា
- ការប្រៀបធៀបការអនុវត្តថវិការដ្ឋ សម្រាប់ខែធ្នូ ឆ្នាំ២០២០
- ការនាំចេញរបស់កូរ៉េខាងត្បូងបន្តកើនឡើងនៅក្នុងខែកុម្ភៈដូចទៅនឹងការព្យាករណ៍ទុករបស់ក្រុមអ្នកសេដ្ឋកិច្ច
- ប្រទេសចិនកើនសន្ទុះក្នុងការប្រជែងយកឈ្នះសហរដ្ឋអាមេរិក ដើម្បីក្លាយជាប្រទេសមហាអំណាចសេដ្ឋកិច្ចពិភពលោក
- ប្រាក់ចំណូលប្រជាជនអាមេរិកបានលោតផ្លោះ១០%ក្នុងខែមករាដោយសារវិធានការជំរុញកំណើនសេដ្ឋកិច្ច ប៉ុន្តែអត្រាអតិផរណា នៅតែស្ថិតក្នុងការត្រួតពិនិត្យ
- តម្លៃប្រេងបានធ្លាក់ចុះជាង ១% ដោយតម្រូវការប្រេងឥន្ធនៈរបស់ប្រទេសចិនថយចុះ ដែលជាការព្រួយបារម្ភមួយសម្រាប់ការផ្គត់ផ្គង់ប្រេងរបស់អង្គការនៃប្រទេសនាំចេញប្រេង (OPEC)


ពិនិត្យ និងកែសម្រួលដោយ

- សួន ពុធថាវី អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- គឹម សុចិត្រា អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- ណុប ចាន់ធី ប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា
- ម៉ែន ខែមវរៈ អនុប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា

ចងក្រង និងបូកសរុបដោយ

- ធីម ប៊ុនធឿន ប្រធានការិយាល័យវិភាគចំណូល-ចំណាយ

# ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

## ពាណិជ្ជកម្មកម្ពុជាជាមួយសហភាពអឺរ៉ុបមានតម្លៃ ៣,៨ ប៊ីលានដុល្លារ នៅឆ្នាំ ២០២០



ពាណិជ្ជកម្មទ្វេភាគីរវាងកម្ពុជា និងសហភាពអឺរ៉ុប មានតម្លៃ ៣,៨៦៣ ពាន់លានដុល្លារ កាលពីឆ្នាំមុន ដែលជាការធ្លាក់ចុះយ៉ាងខ្លាំងបើប្រៀបធៀបនឹងតួលេខដែលបានកត់ត្រាក្នុងឆ្នាំ២០១៩ ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ និងការចាកចេញរបស់អង់គ្លេសពីសហគមន៍អឺរ៉ុប (Brexit)។

តាមរយៈទិន្នន័យពីក្រសួងពាណិជ្ជកម្មបានបង្ហាញថា នៅឆ្នាំ២០២០ ប្រទេសកម្ពុជាបាននាំចេញទំនិញទៅសហភាពអឺរ៉ុបចំនួន ៣,២០៣ ពាន់លានដុល្លារ និងនាំចូល ៦៥៩លានដុល្លារ ពីប្លុកពាណិជ្ជកម្មនេះ ខណៈពេលដែលនៅឆ្នាំ២០១៩ ពាណិជ្ជកម្មទ្វេភាគីរវាងកម្ពុជា និងបណ្តាប្រទេសចំនួន២៨ នៅសហភាពអឺរ៉ុបមានតម្លៃប្រមាណ ៦,៧ ប៊ីលានដុល្លារ។

ការធ្លាក់ចុះពាណិជ្ជកម្មរវាងកម្ពុជានិងសហភាពអឺរ៉ុបនេះ ទទួលរងផលប៉ះពាល់យ៉ាងខ្លាំងដោយជំងឺរាតត្បាតកូវីដ-១៩ ដែលបណ្តាលឱ្យតម្រូវការសម្លៀកបំពាក់នៅក្នុងប្លុកនេះធ្លាក់ចុះ និងត្រូវបានរងឥទ្ធិពលផងដែរពីការដក២០% នៃគម្រោង EBA ពីកម្ពុជាកាលពីឆ្នាំមុន។ ទោះបីជាយ៉ាងណា កម្ពុជាក៏បានទទួលប្រព័ន្ធអនុគ្រោះពន្ធ (ប្រព័ន្ធពាណិជ្ជកម្មទូទៅ) ពីចក្រភពអង់គ្លេសដែលអាចនាំចេញទំនិញប្រមាណ ២០% នេះទៅចក្រភពអង់គ្លេសជំនួសវិញកាត់កងជាមួយនឹងការបាត់បង់ពីសហគមន៍អឺរ៉ុប។

សហភាពអឺរ៉ុបជាប់ចំណាត់ថ្នាក់ជាដៃគូពាណិជ្ជកម្មធំទី២ របស់កម្ពុជាក្នុងឆ្នាំ២០១៩ ដែលស្មើនឹង ១១,៩% នៃពាណិជ្ជកម្មសរុបរបស់ប្រទេស ហើយប្រទេសកម្ពុជាគឺជាដៃគូពាណិជ្ជកម្មធំទី៥៤ របស់សហភាពអឺរ៉ុប៕

*ដោយ វត្ថា វង្សខ្មែរ:*

*ប្រភព៖ Khmer Times ចេញផ្សាយថ្ងៃទី០២ ខែមីនាឆ្នាំ២០២១*

## បន្ទះឈីបរបស់ប្រទេសជប៉ុនសម្រាប់ប្រព័ន្ធនាវាកម្ពុជា



ប្រទេសជប៉ុនបានផ្តល់ថវិកាចំនួន ១,១៣២ ប៊ីលានយ៉េន (១០,៨ លានដុល្លារ) ដល់ប្រទេសកម្ពុជាសម្រាប់ការអនុវត្តប្រព័ន្ធចរាចរណ៍នាវានៅកំពង់ផែសមុទ្រទឹកជ្រៅរបស់ព្រះរាជាណាចក្រកម្ពុជាក្នុងខេត្តព្រះសីហនុ ដើម្បីបង្កើនសុវត្ថិភាព និងប្រសិទ្ធភាពដែនសមុទ្រ។ នៅក្នុងជំនួបទ្វេភាគី ឯកឧត្តម **ប្រាក់ សុខុន** រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងឯកអគ្គរដ្ឋទូតជប៉ុន Masahiro Mikami បានចុះហត្ថលេខា និងផ្លាស់ប្តូរឯកសារទាក់ទងនឹងជំនួយអភិវឌ្ឍន៍ឥតសំណងជាផ្លូវការ។

ជំនួយនេះ នឹងចូលរួមចំណែកយ៉ាងសំខាន់ ក្នុងការលើកកម្ពស់សេដ្ឋកិច្ចសង្គមនៅកម្ពុជា ហើយនឹងពង្រីកបន្ថែមទៀតនូវមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ជាពិសេស ជួយកែលម្អសេវាកម្មនៅកំពង់ផែក្រុងព្រះសីហនុដែលជារឿយៗប្រឈមនឹងការកកស្ទះចរាចរណ៍ខ្លាំង តាមរយៈការបង្កើតប្រព័ន្ធត្រួតពិនិត្យការអនុវត្តនាវាឌីជីថល។ ប្រព័ន្ធនេះនឹងអនុញ្ញាតឱ្យទទួលបាននូវព័ត៌មានត្រឹមត្រូវនៅពេលកប៉ាល់យឺតពន្យាពេល ឬ លុបចោល ហើយនឹងងាយស្រួលសម្រាប់ការរៀបចំឯកសារចាំបាច់សម្រាប់ទូទាត់ផងដែរ។

ដោយឡែក នៅក្នុងការដាក់ឯកសារទៅកាន់ទីផ្សារមូលបត្រកម្ពុជា នាពេលថ្មីៗនេះ សហគ្រាសរដ្ឋកំពង់ផែស្វយ័តព្រះសីហនុបានរាយការណ៍ពីការកើនឡើងប្រាក់ចំណូលសុទ្ធ ១៥,៦% ប្រចាំឆ្នាំនៅក្នុងត្រីមាសទី៤ កើនដល់ ២,៧១៨លានដុល្លារ ពីចំនួន ២,៣៤៩ លានដុល្លារ។ ទោះជាយ៉ាងណា ប្រតិបត្តិករកំពង់ផែទឹកជ្រៅបានបង្ហាញពីការធ្លាក់ចុះប្រាក់ចំណូលពីការលក់ ៧,៥៩% ប្រចាំឆ្នាំ៕ *ដោយ វត្តា វង្សវឌ្ឍនៈ*

*ប្រភព៖ Phnom Penh Post ចេញផ្សាយថ្ងៃទី០១ ខែមីនា ឆ្នាំ ២០២១*

## តារាងប្រចាំសប្តាហ៍៖ ការប្រៀបធៀបការអនុវត្តថវិការដ្ឋសម្រាប់ខែធ្នូ ឆ្នាំ២០២០

តារាងខាងក្រោមនេះ បង្ហាញពីការប្រៀបធៀបការប្រមូលចំណូលក្នុងខែធ្នូ ឆ្នាំ២០២០ ដែលរដ្ឋបាលថ្នាក់ជាតិអនុវត្តបាន។ ចំណូលក្នុងស្រុកសរុបមានចំនួនប្រមាណ ១ ៩២៩ ប៊ីលានរៀល ឬ ធ្លាក់ចុះ ៥៣% បើធៀបនឹងខែដូចគ្នានាឆ្នាំ២០១៩ ដែលមានចំនួន ៣ ២៤១ ប៊ីលានរៀល។ ទន្ទឹមនឹងនេះ ក្នុងឆ្នាំ២០២០ ចំណូលក្នុងស្រុកសរុបថ្នាក់ជាតិ អនុវត្តបានចំនួន ២១ ២១០ ប៊ីលានរៀល ឬ ធ្លាក់ចុះ១៧% បើធៀបនឹងរយៈពេលដូចគ្នានាឆ្នាំ២០១៩ ដែលក្នុងនោះ ចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ បានធ្លាក់ចុះ ១៣% និង

៤៦% រៀងគ្នា ប៉ុន្តែចំណូលមូលធនក្នុងស្រុកបានកើនឡើង ២%។ ការធ្លាក់ចុះនេះ ដោយសារការថមថយសកម្មភាពសេដ្ឋកិច្ច ក្នុងបរិការណ៍រីករាលដាលជំងឺកូវីដ-១៩ និងការអនុវត្តវិធានការអន្តរាគមន៍របស់រាជរដ្ឋាភិបាល ដូចជា ការលើកលែងការបង់ពន្ធប្រចាំខែគ្រប់ប្រភេទសម្រាប់វិស័យទេសចរណ៍ និងពន្ធអប្បបរមាសម្រាប់វិស័យអាកាសចរណ៍ជាដើម។ *ដោយ ឈន ហាំ*




*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា*

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### ការនាំចេញរបស់កូរ៉េខាងត្បូង បន្តកើនឡើងនៅក្នុងខែកុម្ភៈ ដូចទៅនឹងការព្យាករណ៍ទុករបស់ក្រុមអ្នកសេដ្ឋកិច្ច



ការនាំចេញរបស់កូរ៉េខាងត្បូងបានបន្តកើនឡើងក្នុងរយៈពេល ៤ខែជាប់គ្នា គិតត្រឹមខែកុម្ភៈ ឆ្នាំ២០២១ ដោយសារការបន្តកើនឡើងនូវតម្រូវការនៃឈីប (memory chip) និងរថយន្ត។ ការណ៍នេះនឹងគាំទ្រដល់ការស្ទុះងើបឡើងវិញនៃការធ្វើពាណិជ្ជកម្មរបស់ ប្រទេសសេដ្ឋកិច្ចធំជាងគេទី៤ នៅអាស៊ីមួយនេះ។

ការនាំចេញបានកើនឡើងចំនួន ៩,៥% គិតជាទឹកប្រាក់ស្មើនឹង ៤៤,៨១ប៊ីលានដុល្លារអាមេរិក ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ដូចគ្នាទៅនឹងការព្យាករណ៍ទុករបស់ក្រុមសេដ្ឋវិទូចំនួន ១២រូប នៅក្នុងការស្ទង់មតិរបស់ទីភ្នាក់ងារសារព័ត៌មាន Reuters ដែលថាការនាំចេញនឹងកើនឡើង ចំនួន ៩,៥% ប៉ុន្តែ កំណើននេះ គឺទាបជាងកំណើនក្នុងខែមករា ដែលមានចំនួន ១១,៤%។

កំណើននៃការនាំចេញនៅក្នុងខែកុម្ភៈត្រូវបានជំរុញដោយការនាំចេញវត្ថុធាតុឧបករណ៍អេឡិចត្រូនិក (semiconductors) ដែលជាទំនិញនាំចេញឈានមុខគេរបស់កូរ៉េខាងត្បូង ជាមួយអត្រា ១៣,២% ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន និងជាកំណើនរយៈពេល ៨ខែជាប់គ្នា។ ខណៈការនាំចេញរថយន្ត ផលិតផលគីមីឥន្ធនៈ(petrochemicals) និងជីវសាស្ត្រសុខភាព (Bio-health) បានកើនឡើង ៤៧%, ២២,៤%, និង ៦២,៥% រៀងៗគ្នា។

ទន្ទឹមនឹងនេះ ការនាំចេញប្រចាំថ្ងៃរបស់កូរ៉េខាងត្បូងជាមធ្យមបានកើនឡើង២៦,៤% បើធៀបនឹងឆ្នាំមុន ដែលជាការកើនឡើងក្នុងកម្រិតខ្ពស់បំផុតក្នុងរយៈពេល

ជាង៣ឆ្នាំ ដោយមិនរាប់បញ្ចូលនូវផលប៉ះពាល់ពីការធ្លាក់ចុះរយៈពេល ៣ថ្ងៃនៃការនាំចេញ អំឡុងថ្ងៃឈប់សម្រាកបុណ្យចូលឆ្នាំប្រពៃណីជាតិកូរ៉េខាងត្បូង។

ចំណែកឯការនាំចូលរបស់កូរ៉េខាងត្បូងបានកើនឡើង ១៣,៩% គិតជាទឹកប្រាក់ស្មើនឹង ៤២,១១ប៊ីលានដុល្លារអាមេរិក ពោលគឺលើសពីការព្យាករណ៍ទុកដែលមានត្រឹមតែ ១២,៣% ប៉ុណ្ណោះ។

ជាលទ្ធផល អតិរេកពាណិជ្ជកម្មមានចំនួន២,៧១ប៊ីលានដុល្លារអាមេរិក នៅក្នុងខែកុម្ភៈ ធ្លាក់ចុះពី៣,៧៦ប៊ីលានដុល្លារអាមេរិក នៃអតិរេកពាណិជ្ជកម្មនៅក្នុងខែមករា ឆ្នាំ២០២១៕ *ដោយ ស៊ិន សុភារ៉ា*

*ប្រភព៖ គេហទំព័រសារព័ត៌មាន reuters ចេញផ្សាយថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១*

## ប្រទេសចិន កើនសន្ទុះក្នុងការប្រជែងយកឈ្នះសហរដ្ឋអាមេរិក ដើម្បីក្លាយជាប្រទេសមហាអំណាចសេដ្ឋកិច្ចពិភពលោក



សេដ្ឋកិច្ចប្រទេសចិនបានកើនឡើងគៀកនឹងគូប្រជែងសេដ្ឋកិច្ចរបស់ខ្លួន គឺសហរដ្ឋអាមេរិកកាលពីឆ្នាំមុន ដោយសម្រេចបាននូវផលិតផលក្នុងស្រុកសរុប (ផ.ស.ស.) ដល់ ១០១,៥៩ទ្រីលានយ័ន ឬស្មើនឹង ១៤,៧៣ទ្រីលានដុល្លារអាមេរិក ក្នុងឆ្នាំ២០២០ ពោលគឺកើនលើសពី ១០០ទ្រីលានយ័ននៃកម្រិតអប្បបរមា ជាលើកដំបូងនេះបើយោងតាមការចេញផ្សាយរបស់ការិយាល័យជាតិស្ថិតិចិន ដែលមានទីតាំងនៅទីក្រុងប៉េកាំង។

សេដ្ឋកិច្ចចិនសម្រេចបាននូវកំណើនក្នុងអត្រា ២,៣% ក្នុងឆ្នាំ២០២០ បើទោះបីជាទទួលរងផលអវិជ្ជមានពីការរាតត្បាតនៃជំងឺកូវីដ-១៩។ ខណៈដែលផលិតផលក្នុងស្រុកសរុប (ផ.ស.ស.) របស់សហរដ្ឋអាមេរិកបានធ្លាក់ចុះចំនួន២,៣% គិតជាទឹកប្រាក់ស្មើនឹង ២០,៩៣ទ្រីលានដុល្លារអាមេរិក។

ជាលទ្ធផលផ.ស.ស. របស់ចិនមានចំនួន ៧០,៤% នៃ ផ.ស.ស.សហរដ្ឋអាមេរិក ដោយកើនឡើងចំនួន ៣,៦ ពិន្ទុភាគរយពីឆ្នាំ២០១៩ ដែលនេះជាការកើនឡើងលើកដំបូងក្នុងរយៈពេលពីរឆ្នាំ។

ទន្ទឹមនឹងនេះ ផ.ស.ស. របស់ចិននាពេលបច្ចុប្បន្នមានចំនួន១៧%នៃផ.ស.ស.ពិភពលោក ពោលគឺកើនឡើងពី ១០% ធៀបក្នុងឆ្នាំ២០១០។

សូមបញ្ជាក់ផងដែរថា ភាពខុសគ្នានៃវិធានការឆ្លើយតបការរាតត្បាតនៃជំងឺកូវីដ-១៩ បានបង្ហាញថា ប្រទេសចិននឹងយកឈ្នះសហរដ្ឋអាមេរិកក្នុងនាមជាប្រទេសមហា

អំណាចសេដ្ឋកិច្ចពិភពលោកឆាប់ជាងការរំពឹងទុក។ យោងតាមការព្យាករណ៍របស់មជ្ឈមណ្ឌលស្រាវជ្រាវសេដ្ឋកិច្ចជប៉ុន ដែលបានធ្វើឡើងកាលពីខែធ្នូ ឆ្នាំ២០២០ ប្រទេសចិនអាចនឹងយកឈ្នះសហរដ្ឋអាមេរិក និងក្លាយជាប្រទេសមហាអំណាចសេដ្ឋកិច្ចពិភពលោកមិនយូរមិនឆាប់នៅឆ្នាំ២០២៨។ គួរកត់សម្គាល់ថា កាលពីឆ្នាំ២០១៩ មជ្ឈមណ្ឌលនេះបានព្យាករណ៍ថា សហរដ្ឋ-អាមេរិកនឹងអាចចាញ់ចិននៅឆ្នាំ២០៣៥៕

*ដោយ ស៊ិន សុភារ៉ា*

*ប្រភព៖ គេហទំព័រសារព័ត៌មាន Nikkei ASIA ចេញផ្សាយថ្ងៃទី០១ ខែ មីនា ឆ្នាំ២០២១*

## សេដ្ឋកិច្ចសកល

### ប្រាក់ចំណូលប្រជាជនអាមេរិកបានលោតផ្លោះ ១០% ក្នុងខែមករា ដោយសារវិធានការជំរុញកំណើនសេដ្ឋកិច្ច ប៉ុន្តែអត្រាអតិផរណានៅតែស្ថិតក្នុងការត្រួតពិនិត្យ



យោងតាមការរាយការណ៍របស់ក្រសួងពាណិជ្ជកម្មរបស់សហរដ្ឋអាមេរិកបានបង្ហាញថា៖ វិធានការជំរុញសេដ្ឋកិច្ចរបស់សហរដ្ឋអាមេរិកបានធ្វើឱ្យប្រាក់ចំណូលសម្រាប់មនុស្សម្នាក់ៗបានកើនឡើងខ្ពស់បំផុត ចាប់តាំងពីខែមេសា ឆ្នាំ២០២០ បើទោះបីជា អត្រាអតិផរណានៅតែមានភាពរឹងមាំក៏ដោយ។

ប្រាក់ចំណូលសម្រាប់មនុស្សម្នាក់ៗបានកើនឡើងក្នុងអត្រា ០,៦% នៅក្នុងខែធ្នូ រួចបន្តកើនឡើងដល់អត្រា ១០% សម្រាប់ខែមករា ជាអត្រាមួយខ្ពស់ជាងការព្យាករណ៍របស់អ្នកសេដ្ឋកិច្ច Dow Jones ដែលមានត្រឹម ៩,៥%។

កំណើនប្រាក់ចំណូលនេះបានមកពីការបន្ថែមនូវការឧបត្ថម្ភចំនួន ៦០០ដុល្លារ ក្នុងម្នាក់ៗ ដែលសភាបានអនុម័តសម្រាប់ប្រជាជនអាមេរិករាប់លាននាក់ រួមជាមួយអត្ថប្រយោជន៍ដល់អ្នកគ្មានការងារធ្វើផងដែរ។ អ្នកទទួលបានការឧបត្ថម្ភនេះ បានធ្វើការចំណាយយ៉ាងឆាប់រហ័ស ដែលជាកត្តាជំរុញឱ្យការលក់រាយកើនឡើង និងការចំណាយសរុបកើនឡើង ២,៤% សម្រាប់ខែមករា ប៉ុន្តែ អត្រានេះទាបជាងការព្យាករណ៍ ដែលមាន២,៥%។ ទិន្នន័យចំណាយសរុបតិចជាងការរំពឹងទុកនេះ គឺកើតមានស្របពេលដែលអត្រានៃការសន្សំសម្រាប់មនុស្សម្នាក់ៗបានកើនឡើងដល់ ២០,៥% ស្មើនឹង៣,៩៣ទ្រីលានដុល្លារ ដែលនេះជាការកើនឡើងក្នុងកម្រិតខ្ពស់បំផុតគិតចាប់តាំងពីខែឧសភាឆ្នាំ២០២០។ ទោះជាយ៉ាងណា ការចំណាយទាំងអស់មិនបានធ្វើឱ្យមានសម្ពាធលើអតិផរណាទេ ដោយសន្ទស្សន៍ថ្លៃចំណាយលើការប្រើប្រាស់ផ្ទាល់ខ្លួនដែលជារង្វាស់នៃអត្រាអតិផរណា ដែលប្រើដោយធនាគារកណ្តាល បានកើនឡើង ០,៣% សម្រាប់ខែកុម្ភៈនេះ ពោលគឺកើនឡើងបន្តិចពីការរំពឹងទុកដែលមានត្រឹម០,២% ប៉ុន្តែអត្រានេះបានកើនឡើងត្រឹមតែ១,៥% ប៉ុណ្ណោះបើធៀបនឹងពេលវេលាដូចគ្នា

នេះកាលពីឆ្នាំមុនៗ ។ តួលេខនេះ គឺដូចគ្នាទាំងអត្រាអតិផរណា នៃទំនិញទាំងអស់ និងអត្រាគោល ដែលមិនរាប់បញ្ចូលតម្លៃអាហារនិងថាមពលដែលងាយនឹងបង្កជាហេតុនាំឱ្យប្រែប្រួលអត្រានេះ។

នៅខែកញ្ញា ធនាគារកណ្តាលបានអនុម័តគោលនយោបាយជាផ្លូវការមួយ ដែលនឹងអនុញ្ញាតឱ្យអតិផរណាកើនឡើងខ្ពស់ជាង ២% ក្នុងរយៈពេលមួយមុនពេលដំឡើងអត្រាការប្រាក់។ សភាត្រៀមនឹងអនុម័ត កម្មវិធីទាំងអស់ ឬផ្នែកខ្លះនៃកម្មវិធីឧបត្ថម្ភសាច់ប្រាក់ចំនួន ១,៩ ទ្រីលានដុល្លារ ដែលនឹងផ្តល់ការទូទាត់ជុំបន្ថែមទៀតដល់អ្នកប្រើប្រាស់ ក៏ដូចជាអត្ថប្រយោជន៍បន្ថែមដល់អ្នកគ្មានការងារធ្វើ ជំនួយដល់រដ្ឋ និងរដ្ឋបាលមូលដ្ឋាន រួមទាំងផ្តល់ថវិកាសម្រាប់កម្មវិធីដែលទាក់ទងនឹងជំងឺកូវីដ-១៩។

លោក Gus Faucher ប្រធានសេដ្ឋកិច្ចវិទូបានលើកឡើងថា៖ អ្នកប្រើប្រាស់នឹងរង់ចាំចំណាយ នៅពេលនិទាឃរដូវដែលអនុញ្ញាតឱ្យមានសកម្មភាពនៅខាងក្រៅផ្ទះ ហើយមនុស្សកាន់តែច្រើនត្រូវបានចាក់វ៉ាក់សាំងប្រឆាំងនឹងជំងឺកូវីដ-១៩។ ការសន្សំកម្រិតខ្ពស់នាពេលបច្ចុប្បន្ន ក៏នឹងជួយដល់កំណើននៃការចំណាយរបស់អ្នកប្រើប្រាស់ក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខទៀតផងដែរ៕*ដោយ សេន ចន្ទី*

*ប្រភព៖ cnbc, ចេញផ្សាយថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២១*

## តម្លៃប្រេងបានធ្លាក់ចុះជាង ១% ដោយតម្រូវការប្រេងឥន្ធនៈរបស់ប្រទេសចិនថយចុះដែលជាការព្រួយបារម្ភក្នុងការផ្គត់ផ្គង់ប្រេងរបស់អង្គការនៃប្រទេសនាំចេញប្រេង (OPEC)



តម្លៃប្រេងបានធ្លាក់ចុះជាង ១% កាលពីថ្ងៃចន្ទ ដោយសារការភ័យខ្លាចថាការប្រើប្រាស់ប្រេងឆៅរបស់ចិនកំពុងធ្លាក់ចុះ ហើយ OPEC អាចនឹងបង្កើនការផ្គត់ផ្គង់ពិភពលោកបន្ទាប់ពីកិច្ចប្រជុំមួយនៅសប្តាហ៍នេះ។

ប្រេងឆៅប្រភេទ Brent មានតម្លៃ ៦៣,៦៩ ដុល្លារ ក្នុងមួយបារ៉ែលធ្លាក់ចុះ ៧៣ សេន ឬ ១,១% ហើយប្រេងឆៅរបស់សហរដ្ឋអាមេរិក West Texas Intermediate (WTI) មានតម្លៃ ៦០,៦៤ ដុល្លារ ក្នុងមួយបារ៉ែល ធ្លាក់ចុះ ៨៦ សេន ឬ ១,៤%។ កំណើនសកម្មភាពរោងចក្រនៅប្រទេសចិនបានធ្លាក់ចុះដល់កម្រិតទាបបំផុតក្នុងរយៈពេល ៩ខែគិតត្រឹមខែកុម្ភៈនេះ ដែលជាការព្រួយបារម្ភចំពោះការទិញប្រេងឆៅនៅប្រទេសចិន និងសម្ពាធនៃតម្លៃប្រេង។

វិនិយោគិនក៏មានការព្រួយបារម្ភផងដែរថា OPEC និងសម្ព័ន្ធមិត្តរបស់ខ្លួន ដែលមានឈ្មោះថា OPEC+ នឹងបង្កើនទិន្នផលប្រេងឆាប់ៗនេះ។ ការព្រួយបារម្ភ គឺថា

ត្រូវធ្វើយ៉ាងណាបញ្ចប់នូវការបន្ថែមបរិមាណនៃការផលិតប្រេងដល់ទៅ ១,៥ លានបារ៉ែលទៅក្នុងទីផ្សារ ឬត្រូវធ្វើយ៉ាងណាដើម្បីនាំយកប្រេងទាំងនោះមកវិញ ចៀសវាងតម្លៃប្រេងកាន់តែធ្លាក់ចុះ។

យោងតាមការស្ទង់មតិរបស់សារព័ត៌មាន Reuters បានបង្ហាញថា ទិន្នផលប្រេងរបស់ OPEC បានធ្លាក់ចុះក្នុងខែកុម្ភៈដោយសារតែការកាត់បន្ថយដោយស្ម័គ្រចិត្តដោយប្រទេសអារ៉ាប់ប៊ីសាអូឌីត បន្ថែមលើការកាត់បន្ថយក្រោមកិច្ចព្រមព្រៀងមួយជាមួយសម្ព័ន្ធមិត្តដោយបញ្ចប់ ការកើនឡើង៧ខែរៀងគ្នា។

កាលពីថ្ងៃព្រហស្បតិ៍មានការពិភាក្សាអំពីការអនុញ្ញាតឱ្យមានប្រេងផៅចំនួន ១,៥លានបារ៉ែល ក្នុងមួយថ្ងៃនៅក្នុងទីផ្សារ។ អ្នកវិភាគ ING បាននិយាយថា OPEC+ ចាំបាច់ត្រូវចៀសវាងបញ្ចេញការផ្គត់ផ្គង់ប្រេងច្រើនពេកនៅលើទីផ្សារ។

ការកើនឡើងនៃការចាក់វ៉ាក់សាំងប្រឆាំងនឹងជំងឺកូវីដ-១៩ ដែលជំរុញសកម្មភាពសេដ្ឋកិច្ចរួមជាមួយកញ្ចប់ជំនួយឧបត្ថម្ភដែលមានទឹកប្រាក់១,៩ទ្រីលានដុល្លារ ត្រូវបានអនុម័តដោយសភាតំណាងសហរដ្ឋអាមេរិកកាលពីថ្ងៃសៅរ៍បានរក្សាតម្លៃទំនិញមិនឱ្យធ្លាក់ចុះទាប។

តម្លៃប្រេងបានកើនឡើង ដោយសារក្តីសង្ឃឹមទាក់ទងនឹងកញ្ចប់ថវិកាជំរុញសេដ្ឋកិច្ចសហរដ្ឋអាមេរិក ដែលត្រូវបានស្នើ នឹងចំណាយសម្រាប់វ៉ាក់សាំង និងការផ្គត់ផ្គង់វេជ្ជសាស្រ្ត រួមទាំងបញ្ជូនជំនួយហិរញ្ញវត្ថុបន្ទាន់ថ្មីដល់គ្រួសារ និងអាជីវកម្មខ្នាតតូច ដែលនឹងជះឥទ្ធិពលដោយផ្ទាល់ទៅលើតម្រូវការថាមពល។ កិច្ចព្រមព្រៀងលើវ៉ាក់សាំងប្រឆាំងនឹងជំងឺកូវីដ-១៩ ឈ្មោះ Johnson & Johnson ក៏ជាកត្តាមួយរួមចំណែកជួយជំរុញទស្សនវិស័យសេដ្ឋកិច្ចផងដែរ៕ *ដោយ សេន ចន្ទី*

*ប្រភព៖ reuters.com ចេញផ្សាយថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១*

## ទិន្នន័យស្រាវជ្រាវសម្រាប់សប្តាហ៍បន្ទាប់

ទិន្នន័យសម្រាប់សប្តាហ៍ខាងមុខនេះ រួមមាន៖ ទុនបម្រុងអន្តរជាតិរបស់ប្រទេសឥណ្ឌូនេស៊ី ការចំណាយគ្រួសារ និងសន្ទស្សន៍សេដ្ឋកិច្ចឈានមុខគេរបស់ប្រទេសជប៉ុន បម្រែបម្រួលការងារនៅតំបន់ចាយប្រាក់អឺរ៉ូ ផលិតកម្មឧស្សាហកម្មរបស់ប្រទេសបារាំង អត្រាអតិផរណា និងហិរញ្ញប្បទានសង្គមសរុបរបស់ប្រទេសចិន ការរំពឹងទុកអតិផរណាទំនិញប្រើប្រាស់នៅប្រទេសអូស្រ្តាលី តុល្យភាពពាណិជ្ជកម្មរបស់ចក្រភពអង់គ្លេស និងការបម្រែបម្រួលការងារពេញម៉ោងនៅប្រទេសកាណាដា៕

ខាងក្រោម គឺជាប្រតិទិនដែលនាយកដ្ឋានស្រាវជ្រាវថវិកានឹងបន្តតាមដាននៅសប្តាហ៍ក្រោយ៖

<u>ថ្ងៃចន្ទ ទី០៨ ខែមីនា ឆ្នាំ២០២១</u>

- ទុនបម្រុងអន្តរជាតិរបស់ប្រទេសឥណ្ឌូនេស៊ី សម្រាប់ខែកុម្ភៈ
- សន្ទស្សន៍សេដ្ឋកិច្ចឈានមុខគេរបស់ប្រទេសជប៉ុន សម្រាប់ខែមករា

<u>ថ្ងៃអង្គារ ទី០៩ ខែមីនា ឆ្នាំ២០២១</u>

- ការចំណាយគ្រួសាររបស់ប្រទេសជប៉ុន ធៀបនឹងឆ្នាំមុន សម្រាប់ខែមករា
- ការបម្រែបម្រួលការងារនៅតំបន់ចាយប្រាក់អឺរ៉ូ ធៀបនឹងត្រីមាសមុន សម្រាប់ត្រីមាសទី៤

ថ្ងៃពុធ ទី១០ ខែមីនា ឆ្នាំ២០២១

- ផលិតកម្មឧស្សាហកម្មរបស់ប្រទេសបារាំង ធៀបនឹងខែមុន សម្រាប់ខែមករា
- អត្រាអតិផរណារបស់ប្រទេសចិន ធៀបនឹងខែមុន សម្រាប់ខែកុម្ភៈ

ថ្ងៃព្រហស្បតិ៍ ទី១១ ខែមីនា ឆ្នាំ២០២១

- ការរំពឹងទុកអតិផរណាទំនិញប្រើប្រាស់នៅប្រទេសអូស្ត្រាលី សម្រាប់ខែមីនា
- ហិរញ្ញប្បទានសង្គមសរុបរបស់ប្រទេសចិន សម្រាប់ខែកុម្ភៈ

ថ្ងៃសុក្រ ទី១២ ខែមីនា ឆ្នាំ២០២១

- តុល្យភាពពាណិជ្ជកម្មរបស់ចក្រភពអង់គ្លេស សម្រាប់ខែមករា
- ការបម្រែបម្រួលការងារពេញម៉ោងនៅប្រទេសកាណាដា សម្រាប់ខែកុម្ភៈ